# ៦. រឿងភិក្ខុជាសម្លាញ់នឹងគ្នាពីររូប

ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុជាសម្លាញ់នឹងគ្នាពីររូប ត្រាស់ព្រះធម្មទេសនានេះថា អប្បមត្តោ បមត្តេសុ (កាលជនទាំងឡាយប្រមាទហើយ មិនប្រមាទ) ដូច្នេះជាដើម ។

បានឮមកថា ភិក្ខុពីររូបនោះ រៀនកម្មដ្ឋានក្នុងសំណាក់ព្រះសាស្តា ហើយចូលទៅកាន់វិហារដែលតាំងនៅក្នុងព្រៃ ។ ក្នុងបណ្តាភិក្ខុពីររូបនោះ ភិក្ខុមួយរូបនាំយកឧសមកអំពីថ្ងៃ បង្កាត់ភ្លើង ហើយអង្គុយអាំងភ្លើងចរចាជាមួយនឹងភិក្ខុក់លោះ និងសាមណេរទាំងឡាយរហូតអស់បឋមយាម ។ ភិក្ខុដែលជាអ្នកធ្វើនូវសមណធម៌ដោយសេចក្តីមិនប្រមាទ រមែងទូន្មាននូវភិក្ខុនេះថា "ម្នាលអាវុសោ អ្នកកុំធ្វើយ៉ាងនេះឡើយ ព្រោះអបាយភូមិ ៤ ដូចជាផ្ទះដែលជាទីដេកនៃបុគ្គលដែលប្រមាទហើយ ធម្មតាព្រះពុទ្ធទាំងឡាយបុគ្គលអួត មិនអាចឲ្យទ្រង់ពេញព្រះទ័យបានឡើយ" ។ លោកមិនស្តាប់ពាក្យដាស់តឿនរបស់ភិក្ខុនោះ ។ ភិក្ខុក្រៅពីនេះគិតថា "ភិក្ខុនេះមិនជឿពាក្យទូន្មានរបស់យើង ទើបមិនប្រាថ្នា (ដាស់តឿន) ភិក្ខុដែលមិនប្រមាទនោះ ទំព្យាយាមបំពេញនូវសមណធម៌ ។ ឯព្រះថេរៈដែលខ្ជិល អាំងភ្លើង

ក្នុងបឋមយាម ក្នុងវេលាដែលភិក្ខុក្រៅពីនេះដើរចង្ក្រមហើយ ចូលទៅកាន់បន្ទប់ ទើបចូលទៅនិយាយថា "អាវុសោមហាកំជិល លោកចូលមកកាន់ព្រៃដើម្បីប្រយោជន៍ដល់ការដេកឬ បុគ្គលកាលរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះពុទ្ធហើយក្រោកឡើងធ្វើសមណធម៌អស់យប់ និងថ្ងៃមិនគួរឬ?" ដូច្នេះហើយក៏ចូលទៅកាន់លំនៅរបស់ខ្លួន ហើយសឹងលក់ទៅ ចំណែកភិក្ខុក្រៅពីនេះសម្រាកក្នុងមជ្ឈិមហើយ ក្រោកឡើងធ្វើសមណធម៌ក្នុងបច្ឆិមយាម ។ ព្រះថេរៈនោះមិនប្រមាទយ៉ាងនោះ មិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទាទាំងឡាយ ។ ភិក្ខុដែលខ្ជិល ញ៉ាំងកាលវេលាឲ្យកន្លងទៅដោយសេចក្តីប្រមាទតែម្យ៉ាង ។ ភិក្ខុទាំងពីររូបនោះ ពេលចេញវស្សាក៏បានទៅកាន់សំណាក់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីដ៏សមគួរមួយ ។ ព្រះសាស្តា ទ្រង់ធ្វើបដិសណ្ឋារៈនឹងភិក្ខុទាំងពីររូបនោះហើយត្រាស់សួរដូច្នេះថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយបំពេញនូវសមណធម៌ដោយសេចក្តីមិនប្រមាទឬ? កិច្ចនៃបព្វជិតរបស់អ្នកទាំងឡាយដល់ទីបំផុតហើយឬ?" ភិក្ខុដែលជាអ្នកប្រមាទក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីមិនប្រមាទរបស់ភិក្ខុនោះ នឹងមានអំពីទីណា? ចាប់តាំង

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.029_att

ពីកាលដែលខ្លួនទៅ លោកក៏ដេក ញុំាងវេលាឲ្យកន្លងទៅហើយ ។ ព្រះសាស្តាត្រាស់សួរថា "ម្នាលភិក្ខុ ចុះអ្នកវិញ?" ភិក្ខុដែលខ្ជិលក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនាំយកឧសមកអំពីថ្ងៃ ចាត់ចែងអំបែងភ្លើង ហើយអង្គុយអាំងរហូតអស់បឋមយាម មិនប្រព្រឹត្តនូវការលក់ មិនញុំាងកាលឲ្យកន្លងហួសទៅដោយការដេកឡើយ" ។ គ្រានោះ ព្រះសាស្តាត្រាស់នឹងភិក្ខុដែលមានសេចក្តីប្រមាទនោះថា "ម្នាលភិក្ខុ អ្នកប្រមាទហើយបណ្តែតបណ្តោយពេលវេលាឲ្យកន្លងទៅ (ទទេៗ) ប៉ុន្តែនិយាយថា ខ្លួនមិនប្រមាទ នឹងធ្វើនូវភិក្ខុដែលមិនប្រមាទហើយ ឲ្យជាអ្នកប្រមាទ ។ ភិក្ខុនោះដូចជាសេះដែលទុព្វល មិនមានសន្ទុះដើរក្នុងសំណាក់នៃបុត្ររបស់តថាគត ឯបុត្ររបស់តថាគតនេះ ដូចជាសេះដែលមានសន្ទុះដើរដ៏លឿនក្នុងសម្នាក់នៃអ្នក" ដូច្នេះ ទើបត្រាស់ព្រះគាថានេះថា ៖

អប្បមត្តោ បមត្តេសុ សុត្តេសុ ពហុជាគរោ
អពលស្សំវ សីឃស្សោ ហិត្វា យាតិ សុមេធសោ ។

បណ្ឌិតមានប្រាជ្ញាមោះមុត កាលពួកបុគ្គលកំពុងប្រមាទ
លោកមិនប្រមាទ កាលពួកបុគ្គលកំពុងដេកលក់ លោក

ភ្ញាក់រឭកច្រើន លោករមែងលះបង់ចោលនូវបុគ្គលបែប

នោះ ដូចសេះលឿន ដែលទៅចោលនូវសេះមានកម្លាំង

ទន់ទាប ដូច្នោះឯង ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា អប្បមត្តោ (មិនប្រមាទ) សេចក្តីថា ឈ្មោះថា អ្នកដល់ព្រមហើយដោយសេចក្តីមិនប្រមាទ ព្រោះជាអ្នកច្រើនទៅដោយសតិ បានដល់ ព្រះខីណាស្រព ។ បទថា បមត្តេសុ (ប្រមាទហើយ) កាលសត្វទាំងឡាយតាំងនៅហើយក្នុងការបណ្តែតបណ្តោយសតិ ។ បទថា សុត្តេសុ (ដេកលក់ហើយ) គឺ (កាលសត្វទាំងឡាយ) ឈ្មោះថាប្រព្រឹត្តក្នុងឥរិយាបថមួយ ព្រោះមិនមានធម៌ជាគ្រឿងភ្ញាក់ គឺសតិ ។ បទថា ពហុជាគរោ (ភ្ញាក់ហើយ) បានដល់ អ្នកតាំងនៅក្នុងធម៌ជាគ្រឿងភ្ញាក់ គឺ ជាអ្នកបរិបូណ៌ដោយសតិ ។ បទថា អពលស្សំវ (សេះមិនមានកម្លាំង) សេចក្តីថា ដូចជាសេះសិន្ធពអាជានេយ្យ ដែលមានសន្ទុះជើងដ៏រហ័ស រត់ចោលនូវសេះដែលមានកម្លាំងខ្សោយ មិនមានសន្ទុះជើង ព្រោះជាសេះខូកជើង ដូច្នោះ ។ បទថា សុមេធសោ (អ្នកមានបញ្ញា) ជាដើម សេចក្តីថា

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.029_att

បុគ្គលអ្នកមានបញ្ញាមុះមុត រមែងបោះបង់ចោលនូវបុគ្គលបែបនោះហើយទៅ ដោយអាគម គឺ បរិយត្តិផង ដោយអធិគម គឺ ការសម្រេចមគ្គផលផង អធិប្បាយថា កាលបុគ្គលអ្នកមានបញ្ញាទន់ខ្សោយ ព្យាយាមរៀនព្រះសូត្រមួយព្រះសូត្រនោះឯង បុគ្គលដែលមានបញ្ញាមុះមុត រមែងរៀនបានមួយវគ្គ រមែងលះចោលដោយអាគម គឺ បរិយត្តិយ៉ាងនេះឯង ។ ម្យ៉ាងទៀត កាលបុគ្គលអ្នកមានបញ្ញាទន់ខ្សោយ កំពុងព្យាយាមធ្វើនូវទីសម្រាកពេលថ្ងៃ និងទីសម្រាកពេលយប់ និងរៀនកម្មដ្ឋានហើយស្វាធ្យាយនោះឯង បុគ្គលអ្នកមានបញ្ញាល្អ ចូលទៅកាន់ទីសម្រាកពេលថ្ងៃ ឬទីសម្រាកពេលយប់ ដែលអ្នកដទៃធ្វើទុកហើយក្នុងកាលមុន ពិចារណានូវកម្មដ្ឋាន រមែងញុំាងសព្វកិលេសឲ្យអស់ទៅ ធ្វើលោកុត្តរធម៌ ៩ ប្រការ ឲ្យនៅក្នុងកណ្ដាប់ដៃបាន បុគ្គលដែលមានបញ្ញាមុះមុត រមែងបោះបង់ចោលនូវបុគ្គលដែលមានបញ្ញាទន់ខ្សោយដោយអធិគម គឺ ការសម្រេចមគ្គផលយ៉ាងនេះ ។ ម្យ៉ាងទៀត បុគ្គលអ្នកមានបញ្ញាល្អ គឺ បោះបង់ចោលនូវបុគ្គលដែលមានបញ្ញាទន់ខ្សោយនោះទុកក្នុងវដ្ដៈ ហើយដក (ខ្លួន) ចេញចាកវដ្ដៈទៅដោយពិត ។

ក្នុងកាលចប់ព្រះគាថា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.029_att

មានសោតាបត្តិផលជាដើម ដោយប្រការយ៉ាងនេះឯង ។

ចប់ រឿងភិក្ខុជាសម្លាញ់និងគ្នាពីររូប

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.029_att